# ឧបសម្ពន្ធ័១:ព្រឹត្តការណ៍ដែលបានកើតឡើង

**ថ្ងៃទី៩-១០កញ្ញា ឆ្នាំ២០១៤:**

ថ្ងៃទី៩កញ្ញា២០១៤ អាជ្ញាធរបានឃុំខ្លួនបុគ្គលិក២រូបរបស់អង្គការសមធម៌កម្ពុជាដោយពុំមានហេតុផលអ្វីសោះ។ លោកស្រីមែក ហ្វូគូសាវ៉ាជាទីប្រឹក្សាអន្តរជាតិ និងលោកសុខលីដាជាបុគ្គលិកកម្ពុជាផ្នែកស្រាវជ្រាវត្រូវបានរាំងដោយអាជ្ញាធរដែនដី និងត្រូវបានបញ្ជូនទៅស្នងការនគរបាលខេត្តខណ:ពេលដែលអ្នកទាំងពីរកំពុងចុះអង្កេតនិ ងស្រង់ទិន្នន័យនៅក្នុងភូមិបុស្ស។

ពួកគេត្រូវបានសាកសួរអំពីសកម្មភាពស្រាវជ្រាវរបស់ខ្លួនអស់រយ:ពេលជាង៣ម៉ោងដែលបន្ទាប់មកលោកសុខ លីដាត្រូវបានដោះលែងពីមន្ទីរឃុំនៅស្នងការនគរបាល។លោកស្រីមែក ហ្វូគូសាវ៉ា ត្រូវបានឃុំខ្លួននៅក្នុងស្នងការនគរបាលអស់រយ:ពេលពេញ១យប់មុនពេលដែលគាត់ត្រូវបានបញ្ជូនបន្តទៅនាយកដ្ឋានអន្តោប្រវេស្តន៍ក្នុងរាជធានីភ្នំពេញដោយកងកំលាំងប្រដាប់អាវុធនាព្រឹកបន្ទាប់។ បន្ទាប់ពីការសាកសួរពីសំណាក់ប្រធាននាយកដ្ឋានអន្តោប្រវេសន៍ លោកស្រីមែក ហ្វូគូសាវ៉ា ក៏ត្រូវបានដោះលែងដោយពុំមានការចោទប្រកាន់អ្វីឡើយនៅម៉ោង៣និង៣០នាទីរសៀល។

មន្ត្រីនគរបាល បានលើកឡើងពីកង្វល់ចំពោះសុវត្ថិភាពរបស់ក្រុមការងារស្រាវជ្រាវព្រមទាំងលោកស្រីមែក ហ្វូគូសាវ៉ាពុំមានលិខិតឆ្លងដែនច្បាប់ដើមនៅជាប់និងខ្លួន ហើយថាទាំងនេះជាមូលហេតុដែលក្រុមការងារត្រូវបានបណ្តេញចេញពីភូមិបុស្ស និងបន្ទាប់មកឃុំខ្លួននិងបញ្ជូនមកភ្នំពេញ។ (សូមអានសេចក្តីប្រកាសរួមទាក់ទងនិងការឃុំខ្លួនបុគ្គលិកអង្គការសមធម៌កម្ពុជាដោយខុសច្បាប់)

**ថ្ងៃពុធទី៨តុលា ឆ្នាំ២០១៤:**

នៅថ្ងៃទី៨ ខែតុលា ឆ្នាំ២០១៤ ក្រុមការងាររបស់អង្គការសមធម៌កម្ពុជាត្រូវបានអាជ្ញាធរខេត្តដែលរួមទាំងលោកឡុង សុគន្ធ ស្នងការរងនគរបាលខេត្តឧត្តរមានជ័យបញ្ជាអោយចាកចេញជាបន្ទាន់នៅពេលដែលពួកគេកំពុងសម្ភាសន៍ប្រជាពលរដ្ឋ ដែលត្រូវបានគេបណ្តេញចេញចំនួន២០នាក់នៅក្នុងភូមិបាក់នឹម ដោយអះអាងថាពុំមានការអនុញ្ញាតជាមុន។ មន្ត្រីនគរបាលបានអោយដឹងថា ដោយសារតែក្រុមការងាររបស់អង្គការសមធម៌កម្ពុជាមិនបានជូនដំណឹងជាមុនដល់អជ្ញាធរមូលដ្ឋានទាក់ទងទៅនឹងការសិក្សាស្រាវជ្រាវរបស់ខ្លួន ដូច្នេះពួកគេចាំបាច់ត្រូវសុំការអនុញ្ញាតពីអភិបាលខេត្តដើម្បីបន្តការងារសម្ភាសន៍របស់ពួកគេ។

លោកស្នងការរងនគរបាលខេត្តក៏បានយល់ច្រឡំយកច្បាប់ប្រឆាំងភេរវកម្ម[1] ដើម្បីធ្វើការរារាំងដល់កិច្ចប្រជុំដែលបានធ្វើឡើងនៅគេហដ្ឋានឯកជនក្នុងភូមិបាក់នឹម។ នៅក្នុងកិច្ចសម្ភាសន៍ជាមួយកាសែត ឌឹ ខេមបូឌាដេលី (The Cambodia Daily) លោកស្នងការនគរបាលខេត្តឧត្តរមានជ័យ លោកម៉ែន ម៉ាលី បានទទួលស្គាល់ថាពុំមានច្បាប់ដែលតំរូវអោយសុំការអនុញ្ញាត្តសម្រាប់ការប្រជុំនៅក្នុងលំនៅដ្ឋានផ្ទាល់ខ្លួននោះទេ តែលោកទទូចថាអង្គការសង្គមស៊ីវិលនៅតែត្រូវសុំការអនុញ្ញាត្ត។[2]

លោកចាន់ វិចិត្រ បានបញ្ជាក់ថាដោយបានចុះបញ្ជីជាមួយក្រសួងមហាផ្ទៃតាំងពីឆ្នាំ២០១២ អង្គការសមធម៌កម្ពុជាត្រូវបានអនុញ្ញាត្តអោយអនុវត្តសកម្មភាពស្របច្បាប់នានានៅទូទាំងព្រះរាជាណាចក្រកម្ពុជាដូចដែលមានចែងក្នុងឯកសារនៃការចុះបញ្ជី។ ហេតុផលទាំងនេះនៅតែត្រូវបានច្រានចោល បើទោះជាច្បាប់ថតចម្លងនៃឯកសារពាក់ពន្ធ័ត្រូវផ្តល់ជូនអាជ្ញាធរខេត្តក៏ដោយ។

---

[1] *ច្បាប់ប្រឆាំងអំពើភេរវកម្ម ឆ្នាំ២០០៧”ទាញយកពី* UNODC <https://www.unodc.org/tldb/showDocument.do?documentUid=8487&node=docs&cmd=add&country=CMB>.

[2] AunPheap and Peter Zsombor“*ប៉ូលីសខេត្តរមានជ័យបំបែកកិច្ចប្រជុំរវាងអង្គការសង្គមស៊ីវិលនិងប្រជាជនដែលត្រូវបានបណ្តេញចេញ”,ខេមបូឌាដេលី(១០តុលា២០១៤) អាចទាញយក:*<http://www.cambodiadaily.com/news/oddar-meanchey-police-break-up-meeting-between-ngo-evictees-69542/>.

នៅម៉ោង២រសៀល លោកសុខ លីដា លោកណេត វីរៈ និងលោកចាន់ វិចិត្រ បានជួបជាមួយអភិបាលក្រុងសំរោង ដែលបានបញ្ជាក់ថាគាត់បានបញ្ឈប់ការជួបប្រជុំនោះ ដោយសារគាត់ពុំបានដឹងច្បាស់អំពីអង្គការសមធម៌កម្ពុជា និងសកម្មភាពរបស់ពួកគេនោះទេ។ បុគ្គលិកអង្គការសមធម៌កម្ពុជាបានឆ្លើយនូវសំនួរជាច្រើនហូរហែតាំងពីឈ្មោះដៃគូររបស់អង្គការ ប្រភពជំនួយ និងសកម្មភាពលំអិតទាំងឡាយ។ ដោយមានការស្នើសុំ ក្រុមការងារបានផ្តល់នូវច្បាប់ថតចម្លងនៃសំណួរសម្រាប់ការសម្ភាសន៍។

លោកអភិបាលក្រុងបានប្រាប់ក្រុមការងារថាគាត់នឹងជួបពិភាក្សាជាមួយអភិបាលខេត្តនៅថ្ងៃបន្ទាប់ដើម្បីអនុញ្ញាត្តអោយក្រុមការងារបន្តការស្រាវជ្រាវ។គាត់បានផ្តល់អនុសាសន៍ថាអង្គការសមធម៌កម្ពុជាគួរតែដូចជាអង្គការសង្គមស៊ីវិលដទៃទៀត ដែលអង្គការទាំងនោះបានផ្តល់នូវលិខិតជូនដំណឹងដល់អាជ្ញាធរស្រុកសំរោងដើម្បីអនុវត្តការងារនៅក្នុងតំបន់រួម ជាមួយកាលវិភាគចុះធ្វើការងារយ៉ាងហោចណាស់១សប្តាហ៍ជាមុន។

**ថ្ងៃព្រហស្បត៍ទី៩តុលា ឆ្នាំ២០១៤:**

នៅម៉ោង១២ថ្ងៃត្រង់លោកអភិបាលរងក្រុងបានប្រាប់លោកសុខ លីដាថាដោយសារអង្គការសមធម៌កម្ពុជា ពុំមានការិយាល័យក្នុងខេត្តឧត្តរមានជ័យ ក្រុមការងារត្រូវតែធ្វើលិខិតស្នើសុំទៅសាលាខេត្ត។ បើមានការយល់ព្រមពីថ្នាក់ខេត្ត នោះអាជ្ញាធរភូមិស្រុកនឹងត្រូវជូនដំណឹងទៅតាមការគួរ។

នៅម៉ោង២រសៀលបុគ្គលិកម្នាក់របស់សមាគមន៍ អាដហុក ដែលជាដៃគូបានទាក់ទងផ្ទាល់ទៅលោកអភិបាលខេត្តតាមរយៈទូរស័ព្ទ ហើយលោកអភិបាលបានអោយដឹងតាមការសន្ទនានោះថា អង្គការសមធម៌កម្ពុជាត្រូវតែដាក់ជូននូវលិខិតស្នើសុំទៅការិយាល័យរបស់គាត់។

**ថ្ងៃសុក្រទី១០តុលា ឆ្នាំ២០១៤:**

វេលាម៉ោង៨ និង៣០នាទីព្រឹកបុគ្គលិកអង្គការសមធម៌កម្ពុជាបានទៅដល់ការិយាល័យអភិបាលខេត្តដើម្បីដាក់លិខិតជូនដំណឹង ដែលរួមមានពត៌មានទាក់ទងនិងបេសកកម្មរបស់អង្គការសមធម៌កម្ពុជាក្នុងខេត្តឧត្តរមានជ័យ។

ភ្លាមៗបន្ទាប់ពីម៉ោង១១និង៣០នាទីព្រឹក ពលរដ្ឋដែលរងផលប៉ះពាល់ក្នុងភូមិបាក់នឹម និងភូមិបុស្សបានមកដល់ការិយាល័យរបស់ សមាគមន៍អាដហុក ដើម្បីបន្តផ្តល់នូវព័ត៌មានសម្រាប់ការស៊ើបអង្កេតរបស់គណៈកម្មាការជាតិដើម្បីសិទ្ធិមនុស្សរបស់ប្រទេសថៃ។ ពួកគេបានអោយដឹងថានគរបាល ដែលបានបោះទីតាំងក្នុងចម្ការអំពៅតាំងពីបុគ្គលិកអង្គការសមធម៌កម្ពុជាចាប់ផ្តើមការងារនៅមូលដ្ឋាននោះ បានព្រមានពួកគេមិនអោយចាកចេញពីភូមិបាក់នឹមឡើយ។ លើសពីនេះទៅទៀត ដើម្បីកុំអោយអ្នកដែលត្រូវបណ្តេញចេញទៅចូលរួមការសម្ភាសន៍នៅទីប្រជុំជនក្រុង មេភូមិបាក់នឹមបានកុហក់សមាជិកសហគមន៍ដោយចេតនាថាបុគ្គលិកអង្គការសមធម៌កម្ពុជាត្រូវបានចាប់ខ្លួនដោយអាជ្ញាធរខេត្ត។

នៅម៉ោង៤និង៣០នាទីរសៀល ២០នាទី បន្ទាប់ពីចាកចេញពីការិយាល័យរបស់សមាគមន៍អាដហុក អ្នកតំណាងសហគមន៍បានប្រាប់លោកសុខ លីដាថាអាជ្ញាធររួមទាំងស្នងការងនគរបាល និងអភិបាលរងក្រុងបានបិទផ្លូវ និងដាក់អ្នកភូមិ១៦នាក់អោយជាប់នៅម្ខាងផ្លូវ។ អាជ្ញាធរបានសាកសួរអ្នកភូមិពីសកម្មភាពរបស់ពួកគេ រួមទាំងអ្នកដែលបានអញ្ជើញពួកគេទៅកាន់ការិយាល័យសមាគមន៍អាដហុក ហើយសួរថាហេតុអ្វីមានការប្រជុំនៅទីនោះ។ បន្ទាប់ពីសាកសួរ យានជំនិះត្រូវបានអនុញ្ញាត្តអោយត្រឡប់ចូលភូមិវិញ។

**ថ្ងៃសៅរ៍ទី១១តុលា ឆ្នាំ២០១៤:**

នៅចន្លោះម៉ោង៩និង៣០នាទីព្រឹក និងម៉ោង២រសៀលបុគ្គលិកអង្គការសមធម៌កម្ពុជាបានធ្វើការសម្ភាសន៍ចំនួន១៦លើក ជាមួយពលរដ្ឋដែលរងផលប៉ះពាល់មកពីភូមិបុស្ស និងភូមិមួយចំនួនទៀតដែលត្រូវបានដឹកជញ្ជូនដោយបុគ្គលិកអង្គការសមធម៌កម្ពុជា និង

សមាគមន៍អាដហុកទៅកាន់ការិយាល័យសមាគមន៍អាដហុកនៅពេលព្រឹកព្រលឹម។ ក្នុងកំឡុងពេលនោះអាជ្ញាធរខេត្តបានដាក់រនាំងបិទផ្លូវរវាងភូមិសំរោង និងភូមិបុស្ស។

បន្ទាប់ពីការសម្ភាសន៍បានបញ្ចប់ លោកចាន់ វិចិត្រ និងបុគ្គលិករបស់សមាគមន៍អាដហុកបានចាកចេញពីភូមិសំរោងតាមរយៈរថយន្តផ្លូវការរបស់អង្គការសមធមិកម្ពុជា ដើម្បីអមដំណើរអ្នកភូមិ១៧នាក់ត្រលប់ទៅភូមិបុស្សវិញ។ នៅពេលធ្វើដំណើរបានប្រហែល៧គីឡូម៉ែត្រពីការិយាល័យរបស់អង្គការអាដហុក ក្រុមការងារបានជួបនិងរនាំងបិទផ្លូវព្រមទាំងរថយន្តប៉ូលីសជាច្រើនគ្រឿង។ភ្នាក់ងាររាយការណ៍ពត៌មានរបស់ទូរទស្សន៍ប៉ុស្ត៍លេខ៣ក៏មានវត្តមាននៅទីនោះដែរ។

នៅចំនុចបិទផ្លូវ នាយនគរបាលចរាចរណ៍ខេត្តឧត្តរមានជ័យ លោកញ៉ុល វុធទាមទាអោយលោកចាន់ វិចិត្រ បង្ហាញប័ណ្ណបើកបររបស់គាត់និងលិខិតចុះបញ្ជីរថយន្ត។លោកចាន់វិចិត្របានផ្តល់នូវប័ណ្ណបើកបររបស់គាត់ប៉ុន្តែលិខិតចុះ បញ្ជីរថយន្តច្បាប់ដើមត្រូវបានរក្សាទុកនៅការិយាល័យកណ្តាលរបស់អង្គការសមធមិកម្ពុជាក្នុងរាជធានីភ្នំពេញ។ នៅពេលសាកសួររកហេតុផលនៃការឃាត់រថយន្តរបស់អង្គការសមធមិកម្ពុជា ប៉ូលីសម្នាក់ទៀតអះអាងថាមានរថយន្តរបស់អង្គការជាច្រើនដែលបានដឹកឈើខុសច្បាប់។

បន្ទាប់ពីឃាត់រថយន្តរបស់ក្រុមការងារអង្គការសមធមិកម្ពុជា នគរបាលពុំបានព្យាយាមឃាត់រថយន្តដទៃទៀតដែលបានឆ្លងកាត់រនាំងបិទផ្លូវនោះទេ។ ក្រោយពីលោកចាន់ វិចិត្របានកត់សម្គាល់ឃើញថា មន្ត្រីនគរបាលចរាចរឃាត់តែរថយន្តរបស់អង្គការសមធមិកម្ពុជានោះ ពួកគេបានចាប់ផ្តើមឃាត់រថយន្តផ្សេងទៀតដោយសើៗនិងប្រញ៉ាប់ប្រញ៉ាល់ ដោយពួកគេគ្រាន់តែអោយរថយន្តទាំងនោះបង្ហាញប័ណ្ណបើកបរប៉ុណ្ណោះ។

នៅពេលដែលលោកញ៉ុល វុធបានឃើញលោកចាន់ វិចិត្របានថតនូវទិដ្ឋភាពឃាត់រថយន្តដទៃទៀត គាត់បានព្យាយាមរឹបអូសយកម៉ាស៊ីនថតរបស់លោកចាន់ វិចិត្រ។ ដោយលោកចាន់ វិចិត្រ មិនព្រមប្រគល់ម៉ាស៊ីនថត នាយនគរបាលចរាចររូបនោះបានដាល់ពោះរបស់គាត់។ ដោយសារតែលោកញ៉ុល វុធបានប្រើប្រាស់អំពើហិង្សាពុំមែនក្នុងន័យការពារខ្លួន អាកប្បកិរិយារបស់គាត់គឺជាអំពើហិង្សាលើរាងកាយដែលជាគំរូអាក្រក់នៃអំពើឃោឃៅក្នុងជួរនគបាល។

បន្ទាប់មកកំលាំងនគរបាលបានរួមដំណើរជាមួយលោកចាន់ វិចិត្រតាមរថយន្តរបស់អង្គការសមធម៌កម្ពុជាទៅកាន់ស្នងការនគរបាលខេត្ត ដែលទីនោះពួកគេបានរង់ចាំរហូតដល់អង្គការសមធម៌កម្ពុជាអាចបង្ហាញនូវច្បាប់ចតចម្លងនៃការចុះបញ្ជីរថយន្ត។ មន្ត្រីនគរបាលចរាចរណ៍អះអាងថាទង្វើរបស់ពួកគេដែលរួមមានការបិទផ្លូវ ការបញ្ឈប់មនុស្សនៅលើផ្លូវ និងការទាមទារកឯកសារច្បាប់ដើម គឺត្រូវបានអនុញ្ញាតក្រោមច្បាប់ចរាចរណ៍។

អស់រយៈពេលជិត៣ម៉ោង បន្ទាប់ពីទទួលបានលិខិតចុះបញ្ជីររថយន្ត មន្ត្រីនគរបាលបានណែនាំអោយលោកចាន់ វិចិត្រ ផ្តិតមេដៃនៅលើរបាយការណ៍គ្រោះថ្នាក់ចរាចរណ៍ចំនួន២។ នគរបាលក៏បានទាមទាអោយមានកិច្ចព្រមព្រៀងផ្ទាល់មាត់ថារាល់រូបភាពនៅក្នុងម៉ាស៊ីនថតរូបត្រូវបានលប់ចោល។ ដោយការភ័យខ្លាចនូវការដាក់គំនៀបបន្ថែមទៀត លោកចាន់ វិចិត្របានយល់ព្រម ហើយគាត់ក៏ត្រូវបានអនុញ្ញាតអោយត្រឡប់មកការិយាល័យរបស់សមាគមន៍អាដហុកវិញជាមួយរថយន្តរបស់អង្គការសមធម៌កម្ពុជា នៅម៉ោង៧.០០យប់។ នៅពេលត្រូវបានសាកសួរពីអ្នកយកពត៌មានអំពីឧប្បត្តិហេតុដែលបានកើតឡើង លោកញ៉ុល វុធ អះអាងថាលោកគ្រាន់តែអនុវត្តច្បាប់ចរាចរណ៍ប៉ុណ្ណោះ។ លោកបន្តទៀតថា លោកចាន់ វិចិត្រពុំមានសិទ្ធិថតរូបភាពគាត់ និងមន្ត្រីរបស់គាត់នៅពេលធ្វើការនោះទេ ប៉ុន្តែលោកបានបដិសេដថាមិនវាយលោកចាន់ វិចិត្រទេ។[3]

អ្នកភូមិម្នាក់ដែលត្រូវបានបណ្តេញចេញពីភូមិអូរបាត់មាន់ ទើបបានដឹងនៅពេលក្រោយមកថាប្រធានភូមិបានប្រាប់អ្នកភូមិផ្សេងទៀតថា គាត់ត្រូវបានចាប់ខ្លួនក្នុងភូមិសំរោងដែលជាថ្មីម្តងទៀតក្នុងន័យផ្សព្វផ្សាយដំណឹងមិនពិតដើម្បីបំភិតបំភ័យដល់អ្នកភូមិ និងរារាំងពួកគាត់កុំអោយសហការជាមួយអង្គការសមធម៌កម្ពុជា។

[3] Mech Dara and Peter Zsombor"*ក្រុមអ្នកសិទ្ធិមនុស្សអះអាងថាការបំពារបំពានក្នុងខេត្តឧត្តរមានជ័យនៅតែបន្តកើតមាន*" , *កាសែតខេមបូឌាដេលី*(*ថ្ងៃទី១៣តុលា ២០១៤*), *អាចទាញយក*: <http://www.cambodiadaily.com/news/rights-group-claims-continued-harassment-in-oddar-meanchey-69650/>.